សុន្ទរកថារបស់ **ឯកឧត្តម លោក ម៉ាសាហ្វ៊ូមី** ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព
របស់ប្រទេសជប៉ុនប្រចាំកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោង ទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
របស់ប្រទេសជប៉ុន

១៤ កុម្ភៈ ២០១២

**សូមគោរព លោកស្រី Elisa Lieke COENEGRACHTS**
**អ្នកតំណាងវិទ្យាស្ថានសហប្រតិបត្តិការដើម្បីការអភិវឌ្ឍន៍ - ភ្នំពេញ**
**សូមគោរព លោកញ៉ឹក គន្ធា ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពង់ធំ**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើ ម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយជាមួយវិទ្យាស្ថានសហប្រតិបត្តិការដើម្បីការអភិវឌ្ឍន៍ - ភ្នំពេញ (ICS-PP) សម្រាប់គម្រោងជំនួយទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិនាថ្ងៃនេះ។

ជំនួយដែលមានទឹកប្រាក់សរុបចំនួន ៥៩,៧៣៤ដុល្លាអាមេរិក ត្រូវបានផ្តល់ជូន សម្រាប់គម្រោង ពង្រីកបណ្តាញទឹកស្អាតរបស់រដ្ឋាករទឹកតាំងក្រសាំងក្នុងខេត្តកំពង់ធំ។

តាមរយៈការស្នើសុំរបស់វិទ្យាស្ថានសហប្រតិបត្តិការដើម្បីការអភិវឌ្ឍន៍ - ភ្នំពេញ (ICS-PP) និងការពិនិត្យលើទីតាំងគម្រោងដោយបុគ្គលិកស្ថានទូត យើងទទួលស្គាល់នូវតម្រូវការបន្ទាន់ក្នុងការពង្រីកបណ្តាញទឹកស្អាតដើម្បីផ្តល់នូវទឹកស្អាតមានសុវត្ថិភាពជូនដល់ប្រជាពលរដ្ឋក្នុងភូមិប្រាសាទ និងភូមិត្រើយម៉្យាប។

វិស័យអាទិភាពមួយនៃកិច្ចសហប្រតិបត្តិការរបស់រដ្ឋាភិបាលជប៉ុនជាមួយព្រះរាជាណាចក្រកម្ពុជាគឺផ្តល់នូវទឹកស្អាតមានសុវត្ថិភាពនៅតាមតំបន់ទីក្រុងដូចជាភ្នំពេញ និងសៀមរាប ក៏ដូចជានៅតាមតំបន់ជនបទ។

ខ្ញុំសង្ឃឹមថា ការសាងសង់ពង្រីកបណ្តាញទឹកស្អាតនេះនឹងជួយធ្វើឲ្យកាន់តែប្រសើរឡើងនូវការទទួលបានទឹកស្អាតសម្រាប់ប្រជាជន៤៥៤គ្រួសារដែលរស់នៅក្នុងភូមិទាំងពីរ។ ខ្ញុំបានដឹងថានៅក្នុងគម្រោងនេះផងដែរ ICS-PP នឹងបើក វគ្គបណ្តុះបណ្តាលស្តីពីសុខភាពនិងអនាម័យ ព្រមទាំងការ ចែកជូនសៀវភៅណែនាំដល់ប្រជាជនក្នុងភូមិ ខ្ញុំរំពឹងថាប្រជាជនក្នុងភូមិនឹងទទួលបានពត៌មានគ្រប់គ្រាន់អំពីរបៀបប្រើប្រាស់ទឹកស្អាតយ៉ាងមានប្រសិទ្ធភាព និងអំពីវិធីបង្ការជំងឺឆ្លង។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាគម្រោងដែលចុះហត្ថលេខានៅថ្ងៃនេះនឹងត្រូវបានអនុវត្តយ៉ាងរលូនដោយ ICS-PP និងថែរក្សាយ៉ាងត្រឹមត្រូវដោយរដ្ឋាករទឹកតាំងក្រសាំង និងប្រជាជនក្នុងភូមិ។ ខ្ញុំសង្ឃឹមថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!